# លិខិតបញ្ជាក់សុក្រឹតភាពនៃសំណៅបកប្រែ

ក្រុមហ៊ុនសូមបញ្ជាក់ថាសំណៅបកប្រែឯកសារស្តីពី "**គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ**" ដែលមានលេខកូដ **001-60677FCOPEK** ពិតជាត្រឹមត្រូវតាមឯកសារភ្ជាប់ចំពោះគ្រប់ខ្លឹមសារមូលដ្ឋានទាំងអស់ប្រាកដមែន។ សេចក្តីបញ្ជាក់នេះពុំបានកំណត់អំពីយថាភាពនៃច្បាប់ដើម ឬអំពីភាពត្រឹមត្រូវនៃព័ត៌មានដែលបានរៀបរាប់នៅក្នុងសំណៅនេះឡើយ។

ភ្នំពេញ ថ្ងៃទី01 ខែសីហា ឆ្នាំ2024

ព្រះរាជាណាចក្រកម្ពុជា
ហ្វឺស-ក្លាស សឹលូសិន អិលធីឌី
FIRST-CLASS SOLUTIONS LTD
ទីស្នាក់ការរាជធានីភ្នំពេញ

**លឹម គ្រុយ**
**អគ្គនាយក**

សមាគមបណ្ដាញយុវជនកម្ពុជា

CAMBODIAN YOUTH NETWORK ASSOCIATION

# គោលនយោបាយស្ដីពី

# ការប្រឆាំងអំពើពុករលួយ

# Anti-Corruption Policy

# គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ

## 1. សេចក្តីផ្តើម

សមាគមបណ្តាញយុវជនកម្ពុជា (CYN) ប្តេជ្ញាគោរពតាមស្តង់ដារនៃភាពបើកចំហ តម្លាភាព និងគណនេយ្យភាពកម្រិតខ្ពស់បំផុតលើគ្រប់កិច្ចការទាំងអស់របស់ខ្លួន។ សមាគមមានគោលបំណងលើកកម្ពស់វប្បធម៌នៃភាពស្មោះត្រង់ និងប្រឆាំងដាច់ខាតទៅនឹងអំពើពុករលួយគ្រប់ទម្រង់ទាំងអស់។

CYN មានប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា ហើយមានលក្ខណៈដូចគ្នាទៅនឹងអង្គការធំៗ និងអង្គការវិមជ្ឈការដទៃទៀតផងដែរ ដែលទំហំ និងលក្ខណៈនៃប្រតិបត្តិការរបស់យើង ធ្វើឱ្យយើងប្រឈមនឹងការខាតបង់ដោយសារអំពើពុករលួយនោះទេ។

ក្រុមគោលដៅនៃគោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយ គឺបុគ្គលិករបស់ CYN។ ក្នុងនាមជាបុគ្គលិកCYN យើងមានកាតព្វកិច្ចគោរពតាមគោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយនេះ ហើយរាល់ការបំពានទៅលើគោលនយោបាយនេះ ត្រូវតែធ្វើការរាយការណ៍តាមរយៈយន្តការបណ្តឹងរបស់ CYN (មានបញ្ជាក់នៅខាងក្រោម)។ គោលនយោបាយនេះមានគោលបំណងដូចខាងក្រោមៈ

- ផ្តល់នូវនិយមន័យដ៏ច្បាស់លាស់អំពីពាក្យថា "អំពើពុករលួយ"
- ផ្តល់នូវសេចក្តីថ្លែងដ៏ច្បាស់លាស់សម្រាប់បុគ្គលិក ក្នុងការហាមឃាត់សកម្មភាពគៃបន្លំគ្រប់រូបភាពទាំងអស់
- ផ្តល់នូវសេចក្តីសង្ខេបដល់បុគ្គលិកអំពីទំនួលខុសត្រូវរបស់ពួកគេក្នុងការកំណត់រកស្ថានភាពដែលប្រឈមទៅនឹងសកម្មភាពគៃបន្លំ និងដើម្បីបង្កើតយន្តការគ្រប់គ្រង និងនីតិវិធីទប់ស្កាត់សកម្មភាពគៃបន្លំនោះ និង/ឬស្រាវជ្រាវរកសកម្មភាពគៃបន្លំនោះនៅពេលមាន

ករណីកើតឡើង។

- ផ្តល់នូវគោលការណ៍ណែនាំសម្រាប់បុគ្គលិកអំពីវិធានការដែលត្រូវអនុវត្ត នៅពេលមានការសង្ស័យអំពីសកម្មភាពគៃបន្លំ។
- ផ្តល់នូវការគោលការណ៍ណែនាំច្បាស់លាស់អំពីទំនួលខុសត្រូវក្នុងការអនុវត្តការស៊ើបអង្កេតទៅលើសកម្មភាពពាក់ព័ន្ធនឹងអំពើពុករលួយ។
- ផ្តល់ការការពារបុគ្គលិក នៅក្នុងកាលៈទេសៈដែលពួកគេអាចក្លាយជាជនរងគ្រោះដោយសារការរាយការណ៍ ឬការធ្វើជាសាក្សីចំពោះសកម្មភាពគៃបន្លំណាមួយ។

ឯកសារនេះមានគោលបំណងផ្តល់ជាការណែនាំ ហើយត្រូវអានអមជាមួយនឹង៖

- គោលនយោបាយធនធានមនុស្សដែលពាក់ព័ន្ធ
- គោលនយោបាយ និងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការរាយការណ៍អំពីការគៃបន្លំ/ការលួយ និងការឆ្វេសប្រហែស

ឯកសារនេះ នឹងត្រូវពិនិត្យឡើងវិញតាមកាលកំណត់ ដើម្បីកំណត់ថារាល់ចំណុចដែលមាននៅក្នុងឯកសារនៅមានអត្ថប្រយោជន៍ មានភាពពាក់ព័ន្ធ និងនៅមានប្រសិទ្ធភាព។

## 2. និយមន័យ

CYN កំណត់និយមន័យនៃពាក្យ អំពើពុករលួយថាជា៖

> "ការលួច ឬការប្រព្រឹត្តិមិនត្រឹមត្រូវលើមូលនិធិ និងធនធានផ្សេងៗរបស់ CYN ដែលធ្វើឡើងដោយបុគ្គលិក ឬភាគីទីបី ដែលអាច ឬអាចនឹងមិនមានការពាក់ព័ន្ធនឹងការក្លែងបន្លំរបាយការណ៍ហិរញ្ញវត្ថុ ឬកំណត់ត្រា ដើម្បីបិទបាំងការលួច ឬការប្រព្រឹត្តិមិនត្រឹមត្រូវនោះ។"

ឧទាហរណ៍ អំពើពុករលួយ រួមមានជាអាទិ៍ដូចខាងក្រោម៖

- ការលួចមូលនិធិ ឬទ្រព្យសម្បត្តិផ្សេងទៀតរបស់ CYN
- ការក្លែងថ្លៃចំណាយ ឬការចំណាយ
- ការបន្លំ ឬការកែប្រែឯកសារ

- ការបំផ្លាញ ឬដកកំណត់ត្រាចេញ
- ការប្រើប្រាស់ទ្រព្យសម្បត្តិរបស់CYN ក្នុងគោលបំណងផ្ទាល់ខ្លួនដែលមិនសមរម្យ
- បុគ្គលិកស្នើសុំ ឬទទួលយកសាច់ប្រាក់ អំណោយ ឬអត្ថប្រយោជន៍ផ្សេងៗពីភាគីទីបី ដើម្បីជាការដោះដូរទៅតាមការចង់បានរបស់ភាគីទីបីពាក់ព័ន្ធនឹងការធ្វើការងារជាមួយ CYN។
- ការគំរាមហែកកេរ្តិ៍ ឬការជំរិត
- ទំនាស់ផលប្រយោជន៍
- ការបង់ថ្លៃ ឬថ្លៃសេវាច្រើនហួសហេតុទៅកាន់ភាគីទីបីដើម្បីទទួលបានប្រយោជន៍ផ្ទាល់ខ្លួន

3. គោលនយោបាយរបស់ CYN

អំពើពុករលួយគ្រប់ទម្រង់ទាំងអស់គឺជាទង្វើមិនត្រឹមត្រូវ និងមិនអាចទទួលយកបានសម្រាប់ CYN នោះទេ នេះដោយសារតែនៅពេលដែលអំពើពុករលួយកើតឡើង៖

- វាមិនត្រឹមតែជាការខាតបង់របស់ CYN ប៉ុណ្ណោះទេ ប៉ុន្តែនៅទីបំផុតវាគឺជាការខាតបង់ដល់អ្នកទទួលផលរបស់យើង អ្នកដែលរស់នៅក្នុងភាពក្រីក្រខ្លាំង និងប្រជាជនលើពិភពលោកដែលកំពុងមានតម្រូវការខ្លាំងបំផុត
- វាអាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើកេរ្តិ៍ឈ្មោះរបស់យើង ទំនុកចិត្តរបស់ម្ចាស់ជំនួយ រួមទាំងអ្នកទទួលផលរបស់យើងផងដែរ។

CYN មានគោលបំណងលុបបំបាត់រាល់អំពើពុករលួយចេញពីសកម្មភាពរបស់ខ្លួន។ រាល់សញ្ញាដែលបង្ហាញថាមានអំពើពុករលួយ នឹងត្រូវធ្វើការស៊ើបអង្កេត និងដោះស្រាយយ៉ាងម៉ឺងម៉ាត់ និងមានការត្រួតពិនិត្យល្អិតល្អន់។

4. ទំនួលខុសត្រូវរបស់បុគ្គលិក

ក. គណៈកម្មាធិការផ្នែកប្រតិបត្តិការ

គណៈកម្មការផ្នែកប្រតិបត្តិការ (EC) មានទំនួលខុសត្រូវក្នុងការសិក្សាស្វែងយល់អំពីប្រភេទនៃអំពើពុករលួយដែលអាចនឹងកើតឡើងនៅក្នុងតំបន់របស់ពួកគេ ត្រូវមានការប្រុងប្រយ័ត្នចំពោះសញ្ញានៃអំពើពុករលួយ ឬសកម្មភាពមិនសមស្រប ហើយត្រូវបន្តរក្សាការត្រួតពិនិត្យដើម្បីបញ្ចៀសបញ្ហាទាំងនេះកុំឱ្យកើតឡើង។

គណៈកម្មការផ្នែកប្រតិបត្តិការ (EC) ត្រូវតែធានាថា គ្រប់បុគ្គលិកទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួន បានទទួលនូវឯកសារគោលនយោបាយនេះជាភាសាដែលពួកគេអាចយល់បាន ហើយត្រូវមានការបញ្ជាក់ទទួលស្គាល់ថាបានទទួលឯកសារនោះ។

គណៈកម្មការផ្នែកប្រតិបត្តិការ (EC) ត្រូវលើកទឹកចិត្តបុគ្គលិករបស់ខ្លួនឱ្យរាយការណ៍អំពីបញ្ហាអំពើពុករលួយដែលសង្ស័យ។

ខ. បុគ្គលិកទាំងអស់

បុគ្គលិកទាំងអស់ ត្រូវមានទំនួលខុសត្រូវក្នុងការអនុវត្តការងាររបស់ពួកគេ នៅក្នុងលក្ខណៈមួយដែលជួយបង្ការអំពើពុករលួយកុំឱ្យកើតមានឡើងនៅកន្លែងធ្វើការ។ បុគ្គលិកត្រូវតែមានការប្រុងប្រយ័ត្នចំពោះការកើតមានអំពើពុករលួយ ត្រូវចាប់អារម្មណ៍ដឹងថាប្រតិបត្តិការ ឬឥរិយាបថមិនប្រក្រតីអាចជាសញ្ញានៃអំពើពុករលួយ ហើយត្រូវរាយការណ៍អំពីករណីអំពើពុករលួយដែលអាចកើតមាននោះទៅតាមយន្តការដូចមានរៀបរាប់ខាងក្រោម។

## 5. ការរាយការណ៍អំពីករណីពុករលួយដែលសង្ស័យ

បុគ្គលិក តម្រូវឱ្យរាយការណ៍អំពីករណីពុករលួយដែលខ្លួនសង្ស័យ។ ប្រសិនបើករណីសង្ស័យនោះពាក់ព័ន្ធនឹងថវិកាចាប់ពី 10 ដុល្លារឡើងទៅ បុគ្គលិកត្រូវរាយការណ៍ដូចខាងក្រោម៖

- បុគ្គលិកហាត់ការ ជំនួយការ/មន្ត្រី/មន្ត្រីជាន់ខ្ពស់៖ រាយការណ៍ទៅកាន់អ្នកសម្របសម្រួល
- អ្នកសម្របសម្រួល៖ រាយការណ៍ទៅកាន់ប្រធានផ្នែកកម្មវិធី/ប្រធានផ្នែកប្រតិបត្តិការ
- ប្រធានផ្នែកកម្មវិធី/ប្រធានប្រតិបត្តិ៖ រាយការណ៍នៅកាន់ប្រធានប្រតិបត្តិ
- ប្រធានប្រតិបត្តិ៖ រាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល

ករណីអំពើពុករលួយដែលសង្ស័យពាក់ព័ន្ធនឹងទឹកប្រាក់ក្រោម 10 ដុល្លារអាមេរិក ត្រូវរាយការណ៍ទៅកាន់ប្រធានផ្នែកប្រតិបត្តិការ។

បុគ្គលិកដែលសង្ស័យអំពីករណីអំពើពុករលួយមិនត្រូវ៖

- ទាក់ទងទៅកាន់បុគ្គលសង្ស័យដោយផ្ទាល់ដើម្បីចង់ដឹងការពិត ទាមទារការពន្យល់ ឬផ្តល់សំណងឡើយ។
- ពិភាក្សាអំពីបញ្ហានេះជាមួយនឹងអ្នកផ្សេងនៅក្នុង CYN ក្រៅពីអ្នកដែលបានរៀបរាប់ខាងលើ។
- ពិភាក្សាអំពីបញ្ហានេះជាមួយនឹងអ្នកផ្សេងនៅខាងក្រៅCYN លើកលែងតែមានការតម្រូវដោយច្បាប់។

ប្រសិនបើស្ថិតក្នុងកាលៈទេសៈណាមួយ ដែលការរាយការណ៍អំពីករណីសង្ស័យខាងលើមិនអាចអនុវត្តបានទេ ឬប្រសិនបើបុគ្គលដែលត្រូវរាយការណ៍ជូននោះ មិនអាចផ្តល់ជំនួយអ្វីបានទេ សូមធ្វើការរាយការណ៍អំពីបញ្ហានេះទៅកាន់ខ្សែទូរសព្ទផ្តល់ជំនួយសម្ងាត់របស់ CYN តាមរយៈអ៊ីមែល៖ complaint@cyncambodia.org

## 6. ការដោះស្រាយការរាយការណ៍ករណីអំពើពុករលួយដែលសង្ស័យ

ករណីសង្ស័យអំពីអំពើពុករលួយ នឹងត្រូវពិនិត្យដោះស្រាយយ៉ាងម៉ត់ចត់ដោយ CYN។ CYN រំពឹងថាគណៈកម្មការផ្នែកប្រតិបត្តិការ (EC) របស់ខ្លួននឹងដោះស្រាយករណីនៃការរាយការណ៍អំពីអំពើពុករលួយដែលសង្ស័យនេះដោយតឹងរឹង និងឆាប់រហ័ស ប្រសិនអំពើពុករលួយនោះពាក់ព័ន្ធនឹងទំហំទឹកប្រាក់លើសពី 10 ដុល្លារអាមេរិក។

គណៈកម្មការផ្នែកប្រតិបត្តិការ (EC) ដែលទទួលបានការរាយការណ៍អំពីករណីអំពើពុករលួយដែលសង្ស័យ ត្រូវធ្វើការជូនដំណឹងភ្លាមៗអំពីបញ្ហានោះ និងលើកឡើងអំពីវិធានការដែលត្រូវអនុវត្តទៅកាន់៖

- អ្នកសម្របសម្រួល៖ រាយការណ៍ទៅកាន់គណៈកម្មការផ្នែកប្រតិបត្តិការ (EC)
- គណៈកម្មការផ្នែកប្រតិបត្តិការ (EC)៖ រាយការណ៍ទៅកាន់ប្រធានប្រតិបត្តិ

- ប្រធានប្រតិបត្តិ៖ រាយការណ៍ទៅកាន់ក្រុមប្រឹក្សាភិបាល

ការជូនដំណឹងភ្លាមៗនេះ ធ្វើឡើងក្នុងគោលបំណងដើម្បីចែករំលែកបទពិសោធន៍នៃស្ថានភាពស្រដៀងគ្នាដែលអាចធ្លាប់កើតមានឡើងនៅកន្លែងផ្សេងៗ។

## 7. គោលការណ៍ណែនាំស៊ើបអង្កេត

ដោយពិគ្រោះយោបល់ជាមួយនឹងបុគ្គលដែលបានជូនដំណឹង ត្រូវរៀបចំឱ្យមានការស៊ើបអង្កេតគ្រប់ជ្រុងជ្រោយលើបញ្ហានេះ។ ខាងក្រោមនេះ គឺជាទំនួលខុសត្រូវក្នុងការគ្រប់គ្រងការស៊ើបអង្កេត៖

- គណៈកម្មការផ្នែកប្រតិបត្តិការ (EC)៖ ប្រធានប្រតិបត្តិ ប្រធានផ្នែកកម្មវិធី ប្រធានផ្នែកប្រតិបត្តិការ និងប្រតិភូបុគ្គលិក
- ក្រុមប្រឹក្សាភិបាល៖ សមាជិកក្រុមប្រឹក្សាភិបាល

ការស៊ើបអង្កេតត្រូវធ្វើឡើងដោយបុគ្គលិក CYN ឯករាជ្យដែលមានបទពិសោធន៍សមស្រប ឬដោយភាគីឯករាជ្យទីបី។ ការស៊ើបអង្កេតចាំបាច់ត្រូវធ្វើឡើង ដោយមិនគិតអំពីទំនាក់ទំនងរបស់បុគ្គលជាមួយនឹង CYN មុខតំណែង ឬរយៈពេលបំពេញការងារនោះទេ។ ក្នុងអំឡុងពេលស៊ើបអង្កេត បុគ្គលិកដែលត្រូវគេសង្ស័យនោះ នឹងត្រូវបានផ្អាកពីការងាររបស់ខ្លួនរហូតទាល់តែការស៊ើបអង្កេតត្រូវបានបញ្ចប់។

ត្រូវតែអនុវត្តការការពារបុគ្គលិកដែលបានរាយការណ៍នៅក្នុងគ្រប់ករណីទាំងអស់៖ សូមមើលចំណុចខាងក្រោម។

រាល់ការងាររបស់ក្រុមការងារស៊ើបអង្កេតទាំងអស់ត្រូវមានការចងក្រងជាឯកសារ ក្នុងនោះរាប់បញ្ចូលទាំងពាក្យពេជន៍សម្ភាសន៍ផងដែរ។ សេចក្តីសន្និដ្ឋានអំពីការស៊ើបអង្កេតអំពើពុករលួយនោះត្រូវតែចងក្រងទុកជាឯកសារ។

សមាជិកគណៈកម្មការផ្នែកប្រតិបត្តិការ (EC) ដែលទទួលខុសត្រូវ ត្រូវបញ្ជូនរបាយការណ៍/សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនោះទៅកាន់បុគ្គលដែលត្រូវដឹងព័ត៌មាននោះ - សូមមើលខាងលើ - និងព្រមព្រៀងគ្នាទៅលើការចាត់វិធានការសមស្រប។

បុគ្គលដែលបានរាយការណ៍អំពីករណីសង្ស័យ ត្រូវទទួលបានព័ត៌មានអំពីលទ្ធផលនៃការស៊ើបអង្កេត ប៉ុន្តែការជូនដំណឹងនេះត្រូវធ្វើឡើងតែនៅពេលដែលរបាយការណ៍ និងវិធានដែលបានស្នើឡើងត្រូវបានពិនិត្យសម្រេចជាស្ថាពរប៉ុណ្ណោះ។

8. ការការពារបុគ្គលិក

បញ្ហាដែលបានរាយការណ៍ទៅកាន់ថ្នាក់គ្រប់គ្រង និងខ្សែទូរសព្ទផ្តល់ជំនួយ នឹងត្រូវស៊ើបអង្កេតស្របតាមគោលការណ៍ការពារដូចខាងក្រោម។

ការបៀតបៀន ឬការបង្កភាពរងគ្រោះ៖ CYN ទទួលស្គាល់ថា ការសម្រេចចិត្តក្នុងការរាយការណ៍អំពីករណីសង្ស័យអាចនឹងមានការលំបាក ពោលគឺមិនមែនដោយសារតែការភ័យខ្លាចការតបត/ការសងសឹកពីអ្នកត្រូវទទួលខុសត្រូវចំពោះការប្រព្រឹត្តិមិនត្រឹមត្រូវនោះទេ។ យោងតាមគោលនយោបាយធនធានមនុស្ស CYN នឹងមិនអត់ឱនចំពោះការបៀតបៀន ឬការបង្កឱ្យមានជនរងគ្រោះនោះឡើយ ហើយថែមទាំងត្រូវចាត់វិធានការគ្រប់បែបយ៉ាងទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ដើម្បីការពារអ្នកដែលបានលើកឡើងបីបញ្ហាក្នុងគោលបំណងស្មោះត្រង់។

ការរក្សាការសម្ងាត់៖ CYN នឹងខិតខំប្រឹងប្រែង ដើម្បីការពារអត្តសញ្ញាណរបស់បុគ្គល នៅពេលពួកគេលើកឡើងអំពីបញ្ហា ព្រមទាំងមិនចង់បញ្ចេញឈ្មោះរបស់ខ្លួន។ ប៉ុន្តែ យើងគួរយល់ថា ការស៊ើបអង្កេតអំពីការប្រព្រឹត្តិមិនត្រឹមត្រូវ អាចនឹងតម្រូវឱ្យមានការកំណត់អត្តសញ្ញាណប្រភពព័ត៌មាន ហើយអាចតម្រូវឱ្យមានការអះអាងរបស់បុគ្គលដើម្បីយកមកធ្វើជាផ្នែកមួយនៃភស្តុតាង។

ការចោទប្រកាន់អនាមិក៖ CYN មិនលើកទឹកចិត្តឱ្យមានការចោទប្រកាន់អនាមិកនោះទេ។ បញ្ហា

ដែលបានរាយការណ៍បែបអនាមិក នឹងត្រូវពិចារណាទៅតាមឆន្ទានុសិទ្ធិរបស់ CYN។ នៅក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះនឹងត្រូវធ្វើឡើងដោយពិចារណាទៅលើកត្តាខាងក្រោម៖

- ភាពធ្ងន់ធ្ងរនៃបញ្ហាដែលបានលើកឡើង
- ភាពជឿទុកចិត្តនៃការចោទប្រកាន់ និងអង្គហេតុសម្អាង
- លទ្ធភាពដែលអាចបញ្ជាក់អំពីការចោទប្រកាន់ពីប្រភពដែលអាចតាមដានបាន

ការចោទប្រកាន់មិនពិត៖ ប្រសិនបើការចោទប្រកាន់នោះធ្វើឡើងក្នុងគោលបំណងស្មោះត្រង់ ប៉ុន្តែការស៊ើបអង្កេតបង្ហាញថាមិនមានបញ្ហានោះកើតឡើង នោះ CYN សូមធានានឹងមិនមានការចាត់វិធានការណាមួយលើដើមបណ្តឹងនោះទេ។ ប្រសិនបើបុគ្គលនោះធ្វើការចោទប្រកាន់ក្នុងន័យព្យាបាទ ឬធ្វើបាប នោះអាចនឹងមានការពិចារណាអនុវត្តវិធានការវិន័យទៅលើបុគ្គលដែលបានធ្វើការចោទប្រកាន់នោះ។

## 9. សកម្មភាពដែលកើតចេញពីការស៊ើបអង្កេតអំពើពុករលួយ

### 9.1 នីតិវិធីវិន័យ

បុគ្គលដែលត្រូវបានវិនិច្ឆ័យថាជាប់ចោទពីបទប្រព្រឹត្តិអំពើពុករលួយ បានប្រព្រឹត្តិកំហុសធ្ងន់ធ្ងរ ហើយនឹងត្រូវដោះស្រាយស្របតាមគោលនយោបាយបុគ្គលិកស្តីពីវិធានការវិន័យ។ ការចោទប្រកាន់ពីបទប្រព្រឹត្តិអំពើពុករលួយដែលមានភស្តុតាងបញ្ជាក់ច្បាស់លាស់ អាចនឹងឈានទៅដល់ការបញ្ឈប់ពីការងារ។

ប្រសិនបើអាចអនុវត្តទៅបាន CYN នឹងបញ្ជូនករណីអំពើពុករលួយធ្ងន់ធ្ងរទៅកាន់ទីភ្នាក់ងារអនុវត្តច្បាប់ក្នុងប្រទេស ដើម្បីចាប់ផ្តើមដំណើរការនីតិវិធីកាត់ក្តីសំណុំរឿងព្រហ្មទណ្ឌ។ ត្រូវធ្វើការពិចារណាដោយផ្តោតទៅលើបរិបទក្នុងប្រទេស និងផលវិបាកពាក់ព័ន្ធផ្នែកសិទ្ធិមនុស្សដែលកើត

ចេញពីការដំណើរការនីតិវិធីកាត់ក្តីសំណុំរឿងព្រហ្មទណ្ឌលើបុគ្គលពាក់ព័ន្ធ។ គ្រប់ករណីទាំងអស់ សេចក្តីសម្រេចចុងក្រោយថាតើត្រូវ ឬមិនត្រូវកាត់ក្តីនោះ ត្រូវធ្វើឡើងដោយៈ

- គណៈកម្មការផ្នែកប្រតិបត្តិការ (EC)៖ ប្រធានប្រតិបត្តិ
- ក្រុមប្រឹក្សាភិបាល៖ ក្រុមប្រឹក្សាភិបាល

9.2 ការផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រង

ការស៊ើបអង្កេតអំពើពុករលួយ ក៏អាចជាការឆ្លុះបញ្ចាំងអំពីបញ្ហានៃការត្រួតពិនិត្យ និង/ឬការបែងចែក ឬការមិនមានការគ្រប់គ្រងតែម្តង។ វិធានការដែលចាំបាច់សម្រាប់ការកែលម្អប្រព័ន្ធ គួរត្រូវបានកត់ត្រាទុកជាឯកសារនៅក្នុងរបាយការណ៍ស៊ើបអង្កេត រួចត្រូវអនុវត្តនៅពេលរបាយការណ៍នេះត្រូវបានពិនិត្យស្ពាពរ។

9.3 ការស្តារការខាតបង់

នៅពេលCYN ជួបប្រទះនូវការខាតបង់ នោះការសំណងលើអត្ថប្រយោជន៍ ឬសារៈប្រយោជន៍ពេញលេញដែលត្រូវទទួលបាន និងសំណងលើថ្លៃចំណាយនានា គឺត្រូវទាមទារពីបុគ្គល ឬស្ថាប័នដែលទទួលខុសត្រូវចំពោះការខាតបង់នោះ។

ប្រសិនបើបុគ្គល ឬស្ថាប័ន មិនអាច ឬមិនទទួលខុសត្រូវចំពោះការសងសំណងខូចខាតនោះទេ នោះសមាគមអាចនឹងធ្វើការពិចារណាចាត់វិធានផ្លូវច្បាប់ដោយការដាក់ពាក្យបណ្តឹងរដ្ឋប្បវេណី ដើម្បីទាមតារការខាតបង់នោះ។ នេះគឺជាគោលការណ៍បន្ថែមពីលើដំណើរការនីតិវិធីបណ្តឹងព្រហ្មទណ្ឌដែលអាចកើតមាន។

## 10. ការពិនិត្យគោលនយោបាយឡើងវិញ

ដើម្បីរក្សាបាននូវគោលការណ៍អនុវត្តល្អ គណៈកម្មការផ្នែកប្រតិបត្តិការ នឹងធ្វើការពិនិត្យឡើងវិញលើខ្លឹមសារគោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយរៀងរាល់ពីរឆ្នាំម្តង។

## 11. កាលបរិច្ឆេទមានសុពលភាព

គោលនយោបាយស្តីពីការប្រឆាំងអំពើពុករលួយមានសុពលភាពភ្លាមៗ គិតចាប់ពីកាលបរិច្ឆេទដែលក្រុមប្រឹក្សាភិបាលអនុម័តតទៅ។

| **បានពិនិត្យ និងអនុម័តដោយ៖** | **ស្នើឡើងដោយ៖** |
| --- | --- |
| ហត្ថលេខា៖ ............................................. | ហត្ថលេខា៖ ............................................. |
| ឈ្មោះ៖ ..................................................... | ឈ្មោះ៖ ..................................................... |
| តួនាទី៖ ..................................................... | តួនាទី៖ ..................................................... |
| កាលបរិច្ឆេទ៖ ថ្ងៃ.......... ខែ ....... ឆ្នាំ.............. | កាលបរិច្ឆេទ៖ ថ្ងៃ.......... ខែ ....... ឆ្នាំ.............. |